**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

លេខៈ...៤៩៩៥/១៩...ស.ជ.ណ

ថ្ងៃ...អង្គារ...១២...កើត... ខែ ភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កំពង់ធំ ថ្ងៃទី...១០... ខែ ...កញ្ញា... ឆ្នាំ២០១៩

# សេចក្តីជូនដំណឹង

## ស្តីពី

## ការជ្រើសរើស អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តកំពង់ធំ

រដ្ឋបាលខេត្តកំពង់ធំ មានកិត្តិយសសូមជូនដំណឹងដល់ប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ឱ្យបានជ្រាបថាៈ រដ្ឋបាលខេត្តកំពង់ធំនឹងធ្វើការជ្រើសរើស អនុប្រធានការិយាល័យប្រជាពលរដ្ឋចំនួន(១រូប) ដើម្បីបំពេញការងារនៅការិយាល័យប្រជាពលរដ្ឋខេត្តកំពង់ធំ។

ការិយាល័យប្រជាពលរដ្ឋខេត្តកំពង់ធំ មានតួនាទីទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ក្រោមជាតិក្នុងគោលបំណងលើកកម្ពស់អភិបាលកិច្ចល្អក្នុងការផ្តល់សេវា និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពសំដៅបង្កើនជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តកំពង់ធំ នឹងត្រូវជ្រើសរើសតាមរយៈការបោះឆ្នោតដោយ គណៈកម្មាធិការបោះឆ្នោតមួយ ដែលមានសមាសភាពមកពីក្រុមប្រឹក្សាខេត្ត សមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ តំណាងសភាពាណិជ្ជកម្មខេត្ត និងតំណាងអង្គការសង្គមស៊ីវិល។

**១. មុខតំណែងដែលត្រូវជ្រើសរើស**

អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត 01 រូប

**២. លក្ខខណ្ឌ និងលក្ខណសម្បត្តិ**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានបំណងដាក់ពាក្យឈរឈ្មោះជាបេក្ខជន អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត ត្រូវមានលក្ខខណ្ឌ និងលក្ខណៈសម្បត្តិដូចខាងក្រោមៈ

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុចាប់ពី៣៥ឆ្នាំទៅ៦៥ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត

- សញ្ញាបត្រចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលពាក់ព័ន្ធនឹងផ្នែកច្បាប់ ឬរដ្ឋបាល ឬផ្នែកដទៃទៀតពាក់ព័ន្ធនឹងការដោះស្រាយទំនាស់
- មានបទពិសោធក្នុងការងារពាក់ព័ន្ធនឹងផ្នែកច្បាប់ ឬរដ្ឋបាល ឬផ្នែកដទៃទៀតពាក់ព័ន្ធ នឹងការដោះស្រាយទំនាស់យ៉ាងតិច៣ឆ្នាំ
- ជាបុគ្គលស្អាតស្អំ មានកេរ្តិ៍ឈ្មោះល្អ មានការគោរពរាប់អានពីសហគមន៍របស់ខ្លួន
- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងខេត្ត ដែលសាមីជនមានបំណងឈរឈ្មោះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនប្រធាន អនុប្រធានការិយាល័យប្រជាពល រដ្ឋខេត្តៈ

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- សមាជិកក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់
- ព្រះសង្ឃ ឬបុព្វជិតសាសនា
- ជនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈិម ឬឧក្រិដ្ឋ ហើយមិនមាននីតិសម្បទាឡើងវិញ
- ជនដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធចាត់តាំងរបស់គណបក្សនយោបាយណាមួយ។

**៣. តួនាទី ភារកិច្ច**

តួនាទី ភារកិច្ចនៃមុខតំណែងអនុប្រធានការិយាល័យប្រជាពលរដ្ឋ មានកំណត់នៅក្នុងលក្ខខណ្ឌការងារដែលមានភ្ជាប់ជាមួយនឹងសេចក្តីជូនដំណឹង និងពាក្យស្នើសុំ។

**៤. សំណុំឯកសារសម្រាប់ដាក់ពាក្យ**

| | |
|---|---|
| – ពាក្យស្នើសុំ | ១ ច្បាប់ |
| – ប្រវត្តិរូបសង្ខេបមានបិទរូបថត៤x៦ | ១ ច្បាប់ |
| – សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | ១ ច្បាប់ |
| – សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ដែលថតចម្លងតាមច្បាប់ដើម | ១ ច្បាប់ |
| – សញ្ញាបត្រ និងឬវិញ្ញាបនបត្រនានា ដែលថតចម្លងតាមច្បាប់ដើម | ១ ច្បាប់ |
| – រូបថត៤x៦ | ២ សន្លឹក |

**៥. ទីកន្លែងទទួលពាក្យ និងកាលបរិច្ឆេទឈប់ទទួលពាក្យ**

បេក្ខជនដែលមានបំណងចង់ឈរឈ្មោះជាប្រធាន អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត ត្រូវមកទទួលពាក្យ និងដាក់ពាក្យស្នើសុំនៅការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត រៀងរាល់ម៉ោងធ្វើការ ចាប់ពីថ្ងៃ ទី១១ ខែកញ្ញា ឆ្នាំ២០១៩ តទៅ។

កាលបរិច្ឆេទឈប់ទទួលពាក្យស្នើសុំ ត្រឹមថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ វេលាម៉ោង០៥:០០ល្ងាច។

ការចែកពាក្យស្នើសុំ និងលក្ខខណ្ឌការងារ ការដាក់ និងការទទួលពាក្យស្នើសុំពុំតម្រូវឱ្យមានការបង់ប្រាក់ឡើយ។

**៦. ប្រាក់ឧបត្ថម្ភ និងអត្ថប្រយោជន៍**

អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត មានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន ១,១៣៥,០០០ រៀល។

អនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្ត អាចទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀត តាមការកំណត់របស់រដ្ឋបាលខេត្ត។

បេក្ខជនជាស្ត្រី ជនពិការ និងជនជាតិដើមភាគតិច ត្រូវបានផ្តល់អាទិភាពនិងលើកទឹកចិត្តឱ្យដាក់ពាក្យឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងខាងលើនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមប្រជាពលរដ្ឋ និងសាធារណជនទាំងអស់ ដែលមានលក្ខណៈសម្បត្តិសមស្របដូចបានកំណត់នៅក្នុងសេចក្តីជូនដំណឹងនេះ និងមានបំណងឈរឈ្មោះជាបេក្ខជនសម្រាប់មុខតំណែងខាងលើ សូមអញ្ជើញមកទទួល និងដាក់ពាក្យស្នើសុំនៅ ការិយាល័យលេខាធិការក្រុមប្រឹក្សាខេត្ត នៃរដ្ឋបាលខេត្តកំពង់ធំ តាមកាលបរិច្ឆេទដូចបានកំណត់ខាងលើ។

ទំនាក់ទំនងសាកសួរព័ត៌មានបន្ថែម៖ កញ្ញា សុទ្ធ ម៉ានីឡា លេខទូរស័ព្ទ ០៧៨ ៩០៧ ៦១៦ ។

**ជ.គណៈកម្មាធិការបោះឆ្នោត**

**ប្រធាន**

**ឈុន ឈន់**

**ចម្លងជូន ÷**

-ក្រសួងមហាផ្ទៃ

*"ដើម្បីជូនជ្រាប"*

-មន្ទីរ អង្គភាពជំនាញជុំវិញខេត្ត

-រដ្ឋបាលក្រុង-ស្រុក

*"ដើម្បីផ្សព្វផ្សាយ"*

-ឯកសារ កាលប្បវត្តិ